# តារាងការងារប្រកបដោយគ្រោះថ្នាក់ដែលបណ្តាលឱ្យប៉ះពាល់សុខភាព សន្តិសុខ ឬសីលធម៌របស់កុមារ មានចំនួន៣៨ប្រភេទ

១. ការរំលាយ ផ្លុំ ដំ (ស្ពិត) មូរ ដំពង្រាប ឬផ្សារលោហធាតុ
២. ការនេសាទ (ក្នុងទឹក និង លើផ្ទៃទឹកជ្រៅ)
៣. ការមុជទឹកដើម្បី លាងជូត រកខ្យងខ្ចៅ គុជ កើបខ្សាច់ និង គ្រួសអាចម៍ផ្កាយ
៤. ការកាប់ព្រៃឈើ
៥. ការដុតធ្យូង
៦. ការធ្វើការនៅកន្លែងម៉ាស៊ីនចំហាយ ម៉ាស៊ីនបូមខ្សាច់ ម៉ាស៊ីនបញ្ចូលឧស្ម័នក្នុងបំពង់ ឬ ម៉ាស៊ីនផលិតឧស្ម័ន (អាសេទីឡែន) ការដឹកជញ្ជូន និង ការធ្វើការនៅក្នុងកន្លែងយកថ្ម ដូចជា ការខួង អុជ ធ្វើឱ្យផ្ទុះ បំបែកថ្ម ឬ កម្ទេចថ្ម
៧. ការបញ្ជាម៉ាស៊ីនកែច្នៃឈើ
*៨. ការបញ្ជាម៉ាស៊ីនស្ទូច ម៉ាស៊ីនលើក កន្ត្រាក់ ម៉ាស៊ីនមានខ្សែសម្រាប់លើកចុះឡើង ឬ ម៉ាស៊ីនសម្រាប់លើកផ្សេងទៀត*
*៩. ការលើកដាក់ លីសែង យួរកាន់ និង ចលនារបស់ធ្ងន់ៗ (ដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា លេខ ១២៤ សកបយ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម)*
១០. ការពន្លត់អគ្គីភ័យ
១១. ការបើកបរ ឬ ជំនួយការបើកបរ (រួមមាន ការបញ្ឆេះម៉ាស៊ីន ការបញ្ជា ការតំរែតំរង់ ការថែទាំ ឬសកម្មភាពដទៃទៀត ដែលទាក់ទងនឹងការប៉ះទង្គិចរាងកាយដែលបណ្តាលមកពីការបើកបរ) គ្រឿងចក្រ ដូចជា ម៉ាស៊ីនឈូសដី ឬ រុញដី រថយន្តសណ្តោងរ៉ឺម៉ក់ រ៉ូឡូកិនថ្ម ត្រាក់ទ័រសម្រាប់លើកសម្ភារៈ ម៉ាស៊ីនជីកដី ម៉ាស៊ីនប្រមូលរបស់របរ ម៉ាស៊ីនផ្ទុកឥវ៉ាន់ រថយន្តដឹកទំនិញ រថយន្តក្រុង និង រថយន្តតាក់ស៊ី
១២. ការថែទាំ ជួសជុលម៉ាស៊ីនធុនធ្ងន់
១៣. ការធ្វើការនៅក្រោមដី ក្រោមទឹក គុហា ផ្លូវក្រោមដី អណ្តូងរ៉ែ និង ការយករ៉ែ ឬ យកថ្មីក្នុងដី
១៤. ការធ្វើការពាក់ព័ន្ធនឹងវត្ថុដែលមានជាតិផ្ទុះ ជាតិអាស៊ីត កាំជ្រួច ឬ វត្ថុដែលងាយឆេះ លើកលែងតែ ការងារផ្តល់សេវាកម្មនៅក្នុងស្ថានីយ៍ប្រេងឥន្ធនៈ
១៥. ការធ្វើការនៅការដ្ឋានសាងសង់ លើកលែងតែកន្លែងពិសេស ដែលអធិការការងារអាចអនុញ្ញាតឱ្យកុមារធ្វើបាន និង កន្លែងមានសុវត្ថិភាព
១៦. ការធ្វើការនៅកន្លែងរុះរើ និងរំលំរំលាយ
១៧. ការធ្វើការនៅលើជណ្តើរ ឬរន្ទាដែលមានកម្ពស់លើសពី ២.៥០ ម៉ែត្រឡើងទៅ (ដូចជា ការលាបថ្នាំ ជួសជុល ឬ សំណង់ កាត់មែកឈើ បេះផ្លែឈើ)
១៨. ការធ្វើការដែលពាក់ព័ន្ធទៅនឹងមេរោគសាស្ត្រ ដូចជា ការងារនៅមន្ទីរពិសោធន៍ ទឹកលូសម្អុយ និង គំនរសម្រាម
១៩. ការធ្វើការដែលប៉ះពាល់វត្ថុដែលមានជាតិគីមី រូបសាស្ត្រ អេឡិចត្រូម៉ាញេទិច ឬ អ៊ីយ៉ុង ដូចជា

- រូបធាតុដែលមិនឆេះ
- បង់ហ្សែន
- កាត់ម៉ូម
- បារត

- សំណ ស័ង្កសី ឧស្សាហកម្មលោហៈ សំណពណ៌ស និង ថ្នាំលាបមានជាតិសំណ
- សារធាតុវិទ្យុសកម្ម វត្ថុដែលបញ្ចេញពន្លឺ
- កាំរស្មីស្វាយអ៊ុលត្រា កាំរស្មីឡាស៊ែរ និង វិទ្យុបញ្ជូនប្រេកង់

២០. ការធ្វើការដែលពាក់ព័ន្ធទៅនឹងផ្សែង ធូលី ឧស្ម័ន និង សារធាតុដទៃទៀត ដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព

២១. ការបាញ់ថ្នាំសម្លាប់សត្វល្អិត និង ថ្នាំសម្លាប់ស្មៅរុក្ខជាតិផ្សេងៗ

*២២. ការបញ្ជាកម្លាំងម៉ាស៊ីនរវៃខារអំបោះ និង រំអំបោះ*

*២៣. ការជ្រលក់ពណ៌ ការបង្ហើយវាយនភ័ណ្ឌ ការបោកគក់ ការអ៊ុត ដែលការងារទាំង៤យ៉ាងនេះមានប្រើជាតិគីមី*

២៤. ការតម្លើងបរិធានអគ្គីសនី រួមទាំង ការងាររួស ដាក់ខ្សែភ្លើង និង តខ្សែកាប

២៥. ការធ្វើការនៅក្បែរឡដុតកំដៅ រ៉ែ ក្អម ឆ្នាំង ជាផ្នែកមួយនៃដំណើរការរោងចក្រផលិតកែវ កុលាលភាជន៍ និងផលិតឥដ្ឋ

២៦. ការផលិតភេសជ្ជៈដែលមានជាតិស្រវឹងដូចជា ចំហុយស្រា ស្រាបៀរ និង ស្រាទំពាំងបាយជូរ

២៧. ការធ្វើការមួយចំនួននៅកន្លែងកំសាន្ត ដូចជាការបម្រើគ្រឿងស្រវឹង ការគក់ច្របាច់ធ្វើសសៃ ការបម្រើនៅក្នុងក្លឹបរាត្រី ការរាំកំដរភ្ញៀវក្រៅពីការសម្ដែងសិល្បៈ។ ចំពោះការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការធ្វើកម្មសិក្សា និយោជកអាចឱ្យកុមារធ្វើការងារទាំងនេះបាន។

២៨. ការធ្វើការដែលទាក់ទងទៅនឹងល្បែង ដូចជា ការចែកសន្លឹកបៀរ ការស៊ីសងនៅតាមតុល្បែង និងការទទួលលុយភ្នាល់

២៩. ការធ្វើការដែលពាក់ព័ន្ធទៅនឹងការផលិត ឬ ក៏ការដឹកជញ្ជូនថ្នាំញៀន ឬ ផលិតផលឱសថ

*៣០. ការសម្លាប់ស្បែក (កែច្នៃស្បែក)*

៣១. ការធ្វើការជាឆ្មាំសង្គ្រោះនៅកន្លែងហែលទឹក និងធ្នេរងូតទឹកកំសាន្ត

៣២. ការធ្វើការនៅកន្លែងរោងជាងស្មិត

៣៣. ការធ្វើការនៅទីសត្តឃាត (កន្លែងសម្លាប់សត្វ) និង ជាអ្នកផ្ដល់សាច់

៣៤. ការចំហៀវខ្លាញ់ ឬ ប្រេង

៣៥. ការធ្វើការជាបុគ្គលិកសន្តិសុខ

៣៦. ការធ្វើការនៅក្នុងផ្នែកកីឡាដែលប្រកបដោយគ្រោះថ្នាក់ ដូចជា ការបង្ហាត់សេះ ការបង្ហាត់បាញ់ស៊ីប ឬ នៅក្នុងសាលាបាញ់ស៊ីប

៣៧. ការបូជាសព

*៣៨. ការធ្វើការទាំងឡាយដែលស្ថិតនៅក្នុងលក្ខខណ្ឌក្ដៅ ត្រជាក់ ញ័រ សម្លេង និង ពន្លឺភ្លើងមិនប្រក្រតី ដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់។*